# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

1113 : គណនេយ្យនិងសវនកម្ម

| មេពាក្យជាភាសាខ្មែរនិងភាសាបរទេស | សេចក្តីពន្យល់ | កូដ |
|---|---|---|
| ១-បកាសន៍ហិរញ្ញវត្ថុ<br>អ.financial statement<br>បារ. états financiers<br>( m.pl. ) | កំណត់ត្រាផ្លូវការដែលសង្ខេបពីប្រតិបត្តិការនិងស្ថានភាពហិរញ្ញវត្ថុដោយផ្តល់នូវរូបភាពច្បាស់លាស់នៃសុខភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ បកាសន៍ហិរញ្ញវត្ថុ រួមមានបកាសន៍ចំណូល តារាងតុល្យការ និងបកាសន៍លំហូរសាច់ប្រាក់។ | 1113 |
| ២-របាយការណ៍ហិរញ្ញវត្ថុ<br>អ.financial report<br>បារ. rapport financier<br>( n.m. ) | ឯកសារពិស្តារដែលពណ៌នា វិភាគទិន្នន័យ និងវាយតម្លៃដែលផ្អែកជាសំខាន់លើបកាសន៍ហិរញ្ញវត្ថុ ។ | 1113 |
| ៣- បកាសន៍ចំណូល/<br>បកាសន៍ចំណេញខាត<br>អ.income statement/<br>profit and loss statement<br>បារ. compte de résultat<br>( m. )/état des résultats<br>( m. )/relevé de<br>bénéfices et pertes<br>( m. ) | បកាសន៍ហិរញ្ញវត្ថុបង្ហាញអំពីផលចំណូល ចំណាយ ចំណេញ និងខាត ក្នុងការិយបរិច្ឆេទជាក់លាក់មួយ។ | 1113 |
| ៤-តារាងតុល្យការ<br>អ. balance sheet<br>បារ. bilan ( m. ) | បកាសន៍ហិរញ្ញវត្ថុដែលផ្តល់នូវទិដ្ឋភាពរួមនៃទ្រព្យសកម្ម ទ្រព្យអកម្ម និងទ្រព្យម្ចាស់របស់អង្គភាពមួយ នៅក្នុងកាលបរិច្ឆេទជាក់លាក់មួយ។ | 1113 |
| ៥- បកាសន៍លំហូរសាច់ប្រាក់<br>អ. cash flow statement<br>បារ. état des flux de<br>trésorerie ( n.m. ) | បកាសន៍ហិរញ្ញវត្ថុដែលបង្ហាញអំពីចលនាសាច់ប្រាក់ ក្នុងការិយបរិច្ឆេទដោយបញ្ជាក់ពីប្រភពចំណូលនិងគោលដៅ ចំណាយប្រាក់ទៅវិញ។ | 1113 |